# ការងារអភិវឌ្ឍន៍ ប្រកបដោយច្នៃប្រឌិត និងចីរភាព



អង្គការអាយស៊ីស៊ី មិនត្រឹមតែបំរើប្រជាជនកម្ពុជា និងសហគមន៍មូលដ្ឋាន ដើម្បីឲ្យពួកគាត់គេចចេញពីភាពក្រីក្រប៉ុណ្ណោះទេ ថែមទាំងកំពុងធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃជីវិតរបស់ពួកគាត់ទៀតផង។ អនុសញ្ញា និងច្បាប់នៅកម្ពុជា បង្កើតបានជាក្របខ័ណ្ឌសម្រាប់នាំមកនូវគុណភាពដល់ជីវិតរស់នៅរបស់ប្រជាជនតាមរយៈសិទ្ធិ និងយុត្តិធម៌។ ប៉ុន្តែនេះមិនគ្រប់គ្រាន់ទេ ប្រជាជនកម្ពុជាខ្លួនឯង ក៏ត្រូវចូលរួមចំណែកផងដែរ ដោយអនុវត្តគុណតម្លៃស្នូល និងវិធានដែលនឹងបង្កើតជាវប្បធម៌នៅកម្ពុជា។ គុណតម្លៃមួយចំនួនដែលអាយស៊ីស៊ី ចង់ឃើញ រួមបញ្ចូលក្នុងវប្បធម៌កម្ពុជាគឺ ក្តីស្រឡាញ់ ការថែរក្សា និងភាពរួបរួមគ្នា។ សព្វថ្ងៃនេះ ក្នុងសហគមន៍គោលដៅមួយចំនួនរបស់អាយស៊ីស៊ី អ្នកភូមិកំពុងអនុវត្តគុណតម្លៃទាំងនេះ នៅក្នុងភូមិ និងភូមិជិតខាង។

ជាឧទាហរណ៍ អ្នកដឹកនាំក្រុមជំនុំម្នាក់ដែលបានសិក្សាពីគម្រោងអាយស៊ីស៊ី-វីអាយឌីភី(គម្រោង អភិវឌ្ឍន៍សមាហរណកម្មភូមិ) អំពីវិធីដើម្បីនាំមកនូវការផ្លាស់ប្តូរដល់សហគមន៍របស់គាត់តាមរយៈការចូលរួមផ្ទាល់ដោយសហការជាមួយអ្នកភូមិដទៃទៀត និងដោយប្រើប្រាស់ធនធានក្នុងមូលដ្ឋាន។ ឥឡូវនេះ គាត់ត្រូវបានលើកទឹកចិត្ត និងជម្រុញទឹកចិត្តឲ្យចែករំលែកអំពីបទពិសោធន៍របស់គាត់ពីភូមិរបស់គាត់ទៅភូមិមួយផ្សេងទៀត។ គាត់មានពិសោធន៍ គឺថាក្រុមជំនុំ និងសមាជិករបស់គាត់អាចចូលរួមក្នុងការអភិវឌ្ឍសហគមរបស់គេផ្ទាល់ ដោយមិនរង់ចាំអ្នកដទៃមកធ្វើសម្រាប់ពួកគេឡើយ។ អ្នកភូមិ អាចធ្វើកិច្ចការបានច្រើននៅពេលពួកគេចូលរួមជាមួយគ្នា។ លើសពីនេះទៀត បទពិសោធន៍របស់គាត់ គឺថាការងារអភិវឌ្ឍន៍ទាំងអស់មិនចាំបាច់ពឹងផ្អែកទៅលើការផ្តល់មូលនិធិពីខាងក្រៅទាំងស្រុងនោះទេ ប្រសិនបើធនធានក្នុងមូលដ្ឋានត្រូវបានប្រើប្រាស់ និងបង្កើនប្រសិទ្ធភាព នោះវាអាចធ្វើឲ្យសហគមន៍ប្រសើរឡើងបាន។ ក្រៅពីនេះ អ្នកដឹកនាំក្រុមជំនុំនេះ ក៏បានមើលឃើញថា ការងារអភិវឌ្ឍន៍មិនអាស្រ័យលើសាសនាទេ ពុទ្ធសាសនិក គ្រិស្តបរិស័ទ និងអ្នកភូមិដែលមានគោលជំនឿផ្សេងគ្នា ក៏អាចនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានដល់សហគមន៍ទាំងមូលបានដោយធ្វើការរួមគ្នា។ គាត់មានប្រសាសន៍ថា "ខ្ញុំចងចាំជានិច្ចអំពីវិធីចែករំលែកចំណេះដឹងរបស់ខ្ញុំជាមួយអ្នកដទៃ ហើយខ្លួនឯង ខ្ញុំរៀនបានច្រើនដែរ"។

ដូច្នេះ គាត់បានសម្រេចចិត្តឈូងចាប់ភូមិជិតខាងដែលគាត់បានចែករំលែកអំពីការរៀនសូត្រ និងបទពិសោធន៍របស់គាត់។ វាត្រូវចំណាយពេលរាប់ខែមុនពេលគាត់ចាប់ផ្តើមឃើញការរីកចំរើននៅក្នុងភូមិថ្មីនេះ។ ពួកគេ ពិតជាចង់រៀនពីអ្នកដឹកនាំក្រុមជំនុំនេះណាស់ ប៉ុន្តែពួកគេត្រូវយល់ដឹងយ៉ាងច្បាស់អំពីរបៀបជួយខ្លួនឯង និងរបៀបកំណត់ និងទទួលបានប្រយោជន៍ពីធនធានក្នុងមូលដ្ឋានរបស់ពួកគេ។ វាស្ថិតនៅលើផ្លូវវែងឆ្ងាយទៀតសម្រាប់ភូមិថ្មីនេះ ប៉ុន្តែអ្នកដឹកនាំក្រុមជំនុំនៅតែបន្តទៅសួរសុខទុក្ខ និងចែករំលែកជាមួយពួកគេ។ ថ្ងៃមួយ គាត់មានការលើកទឹកចិត្តយ៉ាងខ្លាំង ពីព្រោះយុវជនម្នាក់មកពីភូមិជិតខាងនេះ បានមកប្រឹក្សាយោបល់ជាមួយគាត់ពីរបៀបចូលរួមក្នុងការអភិវឌ្ឍភូមិខ្លួនឯង។ បន្ទាប់ពីការពិភាក្សា និងការឆ្លុះបញ្ចាំងជាមួយអ្នកដឹកនាំក្រុមជំនុំ យុវជននេះបានសម្រេចចិត្តប្រើចំណេះដឹង និងសមត្ថភាពខ្លួន ដើម្បីចាប់ផ្តើមថ្នាក់ភាសាអង់គ្លេសសម្រាប់យុវវ័យនៅក្នុងភូមិ។ គោលបំណងរបស់យុវជននេះ គឺមិនគ្រាន់តែបង្រៀនភាសាអង់គ្លេសដល់យុវវ័យប៉ុណ្ណោះទេ ថែមទាំងជួយយុវវ័យឲ្យយល់ពីសារៈសំខាន់នៃការរួបរួមគ្នា ការស្រឡាញ់ និងការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក។ ក្តីសង្ឃឹមរបស់គាត់ គឺថាយុវវ័យខ្លួនឯង នឹងឃើញពីរបៀបដែលពួកគេអាចចូលរួមចំណែកជាវិជ្ជមានដល់សហគមន៍របស់ពួកគេដោយឈរលើចក្ខុវិស័យរួមគ្នា និងសាមគ្គីភាព។

អាទិភាពរបស់អង្គការអាយស៊ីស៊ី គឺសហការដោយផ្ទាល់ជាមួយក្រុមគោលដៅ ដើម្បីធ្វើឲ្យការងារអភិវឌ្ឍរបស់អាយស៊ីស៊ី មានរយៈពេលយូរប្រកបដោយចីរភាពក្រោមភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់អ្នកមូលដ្ឋាន។ លើសពីនេះទៅទៀត អាយស៊ីស៊ី ចង់ឃើញគំនិតផ្តួចផ្តើម និងវិធីសាស្ត្រដែលត្រូវបានបង្កើតឡើង និងសាកល្បងដោយអាយស៊ីស៊ីត្រូវបានចែករំលែក និងចម្លងតាមមធ្យោបាយណាមួយ ឬនៅកន្លែងថ្មីរបស់ប្រទេសកម្ពុជាដោយមិនផ្អែកលើអ្នកខាងក្រៅ និងហិរញ្ញវត្ថុខាងក្រៅ។

កាលបរិច្ឆេទ៖ កុម្ភៈ ២០១៨